ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ៣៦៥ ព.ណ.កលប.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តន៍ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញលិខិតុបករណ៍ចូលជាសមាជិកនៃពិធីសារទីក្រុងម៉ាឌ្រីដរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ស្តីពី ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ និងបានចូលជាសមាជិក នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._ គោលបំណង**

ប្រកាសនេះ មានគោលបំណងអនុវត្តពិធីសារទីក្រុងម៉ាឌ្រីដ និងនីតិវិធីសម្រាប់ការចុះបញ្ជី និងការពារម៉ាកក្នុងក្របខណ្ឌអន្តរជាតិ។

**ប្រការ ២._ វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។

ប្រកាសនេះ ត្រូវអនុវត្តរួមជាមួយបទប្បញ្ញត្តិទាំងឡាយនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួមទាក់ទងនឹងពិធីសារទីក្រុងម៉ាឌ្រីដ ។

**ប្រការ ៣._ វាក្យសព្ទបច្ចេកទេស**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចតទៅ៖

(១) "ពិធីសារទីក្រុងម៉ាឌ្រីដ" សំដៅដល់ពិធីសារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលត្រូវបានអនុម័តនៅទីក្រុងម៉ាឌ្រីដ នៃប្រទេសអេស្ប៉ាញ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨៩ ដែលប្រទេសកម្ពុជាជាសមាជិកនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥។

(២) "បទប្បញ្ញត្តិរួម" សំដៅដល់បទប្បញ្ញត្តិទាំងឡាយ ក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ និងពិធីសារទីក្រុងម៉ាឌ្រីដ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

(៣) "ភាគីហត្ថលេខី" សំដៅដល់ប្រទេស ឬអង្គការអន្តររដ្ឋាភិបាល ដែលជាសមាជិកនៃពិធីសារទីក្រុងម៉ាឌ្រីដ។

(៤) "នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម" ជាអង្គភាពដែលមានភារកិច្ចក្នុងការចុះបញ្ជី និងការពារម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(៥) "ពាក្យស្នើសុំក្នុងក្របខណ្ឌអន្តរជាតិ" សំដៅដល់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលបានដាក់ពាក្យស្នើសុំនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្នុងនាមជាការិយាល័យដើម ដើម្បីទទួលបានការចុះបញ្ជីម៉ាក និងអត្ថប្រយោជន៍នានាក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(៦) "ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ" សំដៅដល់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលមានអានុភាពក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(៧) "អ្នកស្នើសុំ" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ ឬបរទេស ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្នុងនាមបុគ្គលនោះ។

(៨) "ម្ចាស់ម៉ាក" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ ឬបរទេស ដែលបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិត្រូវបានកត់ត្រាទុកក្នុងបញ្ជីក្របខណ្ឌអន្តរជាតិក្នុងនាមបុគ្គលនោះ។

(៩) "ការជ្រើសរើសប្រទេសបន្ទាប់សម្រាប់ការដាក់ពាក្យ" សំដៅដល់ការជ្រើសរើសប្រទេសកម្ពុជា ឬប្រទេសជាភាគីហត្ថលេខីណាមួយបន្ថែមទៀត បន្ទាប់ពីបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ សំដៅពង្រីកកិច្ចការពារម៉ាក។

(១០) "ច្បាប់ស្តីពី ម៉ាក" សំដៅដល់ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២។

(១១) "អនុក្រឹត្យស្តីពី ម៉ាក" សំដៅដល់អនុក្រឹត្យលេខ ៦៤ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

(១២) "ការិយាល័យអន្តរជាតិ"សំដៅដល់ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

(១៣) "បញ្ជីអន្តរជាតិ" សំដៅដល់ទិន្នន័យផ្លូវការពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលគ្រប់គ្រងដោយការិយាល័យអន្តរជាតិ។

(១៤) "ពាក្យស្នើសុំគោល" សំដៅដល់ពាក្យស្នើសុំចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដែលប្រើប្រាស់ពាក្យស្នើសុំនោះធ្វើជាមូលដ្ឋានសម្រាប់ការដាក់ពាក្យចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(១៥) "ការចុះបញ្ជីគោល" សំដៅដល់ការចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ហើយដែលបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(១៦) "ព្រឹត្តិបត្រផ្លូវការ" សំដៅដល់ព្រឹត្តិបត្រដែលបានបោះពុម្ពផ្សាយម៉ាកដែលបានចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

(១៧) "ការិយាល័យដើម" សំដៅដល់អង្គភាពកម្មសិទ្ធិបញ្ញានៃប្រទេសហត្ថលេខីដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានដាក់ជាលើកដំបូង។

(១៨) "ប្រទេសហត្ថលេខីដែលបានជ្រើសរើស" សំដៅដល់ប្រទេសហត្ថលេខីនៃពិធីសារទីក្រុងម៉ាឌ្រីដ ដែលត្រូវបានជ្រើសរើសសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឬជាប្រទេសហត្ថលេខីដែលត្រូវបានជ្រើសរើសបន្ទាប់។

## ជំពូកទី ២
## សិទ្ធិ និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្នុងលក្ខខណ្ឌព្រះរាជាណាចក្រកម្ពុជាជាការិយាល័យដើម

### ប្រការ ៤._ សិទ្ធិក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬម៉ាកដែលបានចុះបញ្ជីហើយក្នុងនាមបុគ្គលនោះនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មក្នុងនាមជាការិយាល័យដើម អាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ប្រសិនបើរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ៖

(១) ជាជនជាតិខ្មែរ ឬ

(២) មានលំនៅដ្ឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

(៣) មានគ្រឹះស្ថានឧស្សាហកម្ម ឬពាណិជ្ជកម្ម ស្របច្បាប់និងកំពុងដំណើរការក្នុងព្រះរាជាណាចក្រកម្ពុជា។

ពាក្យស្នើសុំ និងឯកសារយោងសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងឯកសារទំនាក់ទំនង រវាងការិយាល័យអន្តរជាតិ និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើជាភាសាអង់គ្លេស។

## ប្រការ ៥._ ឯកសារ និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំ

ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិត្រូវបានកំណត់លក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

(១) ឈ្មោះ អាសយដ្ឋានពិតប្រាកដ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកស្នើសុំ ព្រមទាំងឈ្មោះ អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងលម្អិតរបស់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ប្រសិនបើមាន

(២) គំរូម៉ាកស្របតាមលក្ខខណ្ឌតម្រូវ នៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

(៣) យថាប្រភេទទំនិញនិងសេវា ដែលនឹងត្រូវស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និង

(៤) ប្រទេសហត្ថលេខីដែលត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជី។

អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ MM2 ដែលអាចទាញយកបានពីគេហទំព័រ www.cambodiaip.gov.kh ។

ពាក្យស្នើសុំអាចយកមកដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម រៀងរាល់ម៉ោងធ្វើការ។

## ប្រការ ៦._ តម្លៃដាក់ពាក្យ

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបង់តម្លៃសេវារដ្ឋបាល និងតម្លៃសេវាពាក់ព័ន្ធផ្សេងទៀត តាមប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

## ប្រការ ៧._ តម្លៃចុះបញ្ជីម៉ាកអន្តរជាតិ

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបង់តម្លៃតាមការកំណត់របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

## ជំពូកទី ៣
## នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ
## ដែលព្រះរាជាណាចក្រកម្ពុជាជាការិយាល័យដើម

**ប្រការ ៨._ ការត្រួតពិនិត្យពាក្យស្នើសុំ**

ក្នុងនាមជាការិយាល័យដើម នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវផ្ទៀងផ្ទាត់ព័ត៌មានលម្អិតពាក់ព័ន្ធទាំងឡាយនៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឲ្យដូចទៅនឹងព័ត៌មានលម្អិតដែលមាននៅក្នុងពាក្យស្នើសុំគោល ឬការចុះបញ្ជីគោល ។

**ប្រការ ៩._ ការបញ្ជាក់ភាពត្រឹមត្រូវ**

(១) នៅពេលដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ បានបំពេញតាមលក្ខខណ្ឌកំណត់រួចហើយ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវបញ្ជាក់លើពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិនោះ អំពីភាពត្រឹមត្រូវដោយចុះកាលបរិច្ឆេទទទួលពាក្យស្នើសុំ រួចបញ្ជូនទៅការិយាល័យអន្តរជាតិ។

(២) នៅពេលដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ មិនបានបំពេញតាមលក្ខខណ្ឌកំណត់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មិនត្រូវបញ្ជូនពាក្យស្នើសុំនោះទៅការិយាល័យអន្តរជាតិឡើយ ប៉ុន្តែត្រូវជូនដំណឹងទៅអ្នកស្នើសុំឲ្យធ្វើការកែតម្រូវក្នុងរយៈពេល ប្រាំពីរ(០៧)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខា។

**ប្រការ ១០._ ការអស់សុពលភាពនៃពាក្យស្នើសុំគោល ឬការចុះបញ្ជីគោល**

អនុលោមតាមមាត្រា ៦ នៃពិធីសារទីក្រុងម៉ាឌ្រីដ នៅពេលដែលពាក្យស្នើសុំគោល ឬការចុះបញ្ជីគោលលែងមានសុពលភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាការិយាល័យដើម នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីបញ្ហានេះ និងត្រូវស្នើសុំលុបការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ចំពោះទំនិញនិងសេវាដែលពាក់ព័ន្ធ។

## ជំពូកទី ៤
## នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ
## ដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជី

**ប្រការ ១១._ ការត្រួតពិនិត្យម៉ាកលម្អិត**

នៅពេលដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការត្រួតពិនិត្យម៉ាកលម្អិត ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ១២._ ការបដិសេធបណ្តោះអាសន្នចំពោះកិច្ចការពារម៉ាក**

នៅពេលដែលម៉ាកស្នើសុំចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានបដិសេធជាបណ្តោះអាសន្នចំពោះកិច្ចការពារ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ អំពីការបដិសេធនេះ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម ។ ការជូន

ដំណឹងនេះត្រូវអនុលោមតាមមាត្រា ៥(២)(b) នៃពិធីសារទីក្រុងម៉ាឌ្រីដ ។

អ្នកដាក់ពាក្យស្នើសុំដែលត្រូវបានបដិសេធការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ មានសិទ្ធិតវ៉ារកដំណោះស្រាយនានាស្របតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

### ប្រការ ១៣._ ការបដិសេធបណ្តោះអាសន្នចំពោះកិច្ចការពារម៉ាក ដោយផ្អែកលើបណ្តឹងជំទាស់

នៅពេលដែលមានបណ្តឹងជំទាស់ទៅលើការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីការបដិសេធជាបណ្តោះអាសន្ន ដោយអនុលោមតាមមាត្រា ៥(២)(b) និង ៥(២)(c) នៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

អ្នកដាក់ពាក្យស្នើសុំដែលត្រូវបានបដិសេធការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ មានសិទ្ធិតវ៉ារកដំណោះស្រាយនានាស្របតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

### ប្រការ ១៤._ ការគ្មានមូលដ្ឋានបដិសេធ និងសេចក្តីអះអាងអំពីការផ្តល់កិច្ចការពារ

នៅពេលនាយកដ្ឋានកម្មសិទ្ធិបញ្ញាបានអនុវត្តនីតិវិធីត្រួតពិនិត្យចប់សព្វគ្រប់ ហើយគ្មានមូលដ្ឋានបដិសេធ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវផ្ញើសេចក្តីអះអាងអំពីការផ្តល់កិច្ចការពារម៉ាកនោះ ទៅការិយាល័យអន្តរជាតិឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងឲ្យបានមុនថ្ងៃផុតកំណត់នៃរយៈពេលបដិសេធដោយអនុលោមតាមមាត្រា ៥(២)(b) នៃពិធីសារទីក្រុងម៉ាឌ្រីដ។

### ប្រការ ១៥._ សេចក្តីសម្រេចចុងក្រោយ បន្ទាប់ពីបានជូនដំណឹង អំពីការបដិសេធជាបណ្តោះអាសន្នចំពោះកិច្ចការពារ

#### (១) សេចក្តីសម្រេចចុងក្រោយអំពីការផ្តល់កិច្ចការពារ

ទោះបីជាការបដិសេធជាបណ្តោះអាសន្នចំពោះកិច្ចការពារ ត្រូវបានបញ្ជូនទៅការិយាល័យអន្តរជាតិអនុលោមតាមប្រការ ១២ ឬប្រការ ១៣ ខាងលើរួចហើយក៏ដោយ ក៏នាយកដ្ឋានកម្មសិទ្ធិបញ្ញាអាចធ្វើសេចក្តីសម្រេចចុងក្រោយក្នុងការដកចេញការបដិសេធកិច្ចការពារទាំងស្រុង ឬផ្នែកខ្លះ បន្ទាប់ពីបានត្រួតពិនិត្យលើទឡ្ហីករណ៍ និង/ឬភ័ស្តុតាងនានាពីអ្នកដាក់ពាក្យ។

ក្នុងករណីនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវផ្ញើទៅការិយាល័យអន្តរជាតិនូវសេចក្តីសម្រេចណាមួយ ដូចខាងក្រោម៖

(ក) សេចក្តីសម្រេចដែលបញ្ជាក់ថា ការបដិសេធជាបណ្តោះអាសន្ននោះ ត្រូវបានដកចេញ ហើយម៉ាកនោះ ត្រូវបានផ្តល់កិច្ចការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គ្រប់មុខទំនិញ និងសេវាដែលបានស្នើសុំ ។

(ខ) សេចក្តីសម្រេចដែលបញ្ជាក់ថា ការបដិសេធជាបណ្តោះអាសន្ននោះ ត្រូវបានដកចេញដោយផ្នែកខ្លះ ហើយម៉ាកនោះត្រូវបានផ្តល់កិច្ចការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់

មុខទំនិញនិងសេវាមួយចំនួនដែលបានស្នើសុំ ដោយបញ្ជាក់អំពី យថាប្រភេទ មុខទំនិញ ឬសេវាដែលផ្តល់កិច្ចការពារ។

(២) **សេចក្តីសម្រេចចុងក្រោយអំពីការបដិសេធកិច្ចការពារទាំងស្រុង**

អនុលោមតាមប្រការ ១២ ឬប្រការ ១៣ ខាងលើ និងនៅពេលដែលនីតិវិធីត្រួតពិនិត្យម៉ាកមុនពេលចុះបញ្ជីត្រូវបានបញ្ចប់ នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ អំពីសេចក្តីសម្រេចក្នុងការបដិសេធកិច្ចការពារទាំងស្រុង ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវបញ្ជូនសេចក្តីសម្រេចចុងក្រោយនេះទៅការិយាល័យអន្តរជាតិ។

## ប្រការ ១៦._ សេចក្តីសម្រេចបន្ថែមទៅលើសេចក្តីសម្រេចចុងក្រោយដែលប៉ះពាល់ដល់កិច្ចការពារម៉ាក

ក្នុងករណីមានបណ្តឹងតវ៉ាលើសេចក្តីសម្រេចចុងក្រោយ ក្នុងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ហើយមានការចេញសេចក្តីសម្រេចបន្ថែមទាក់ទងដល់កិច្ចការពារម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីសេចក្តីសម្រេចបន្ថែមនោះ។

## ប្រការ ១៧._ ប្រសិទ្ធភាពនៃការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើស ត្រូវមានអានុភាពដូចគ្នានឹងការដាក់ពាក្យផ្ទាល់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ហើយមានប្រសិទ្ធភាពអនុវត្តគិតចាប់ពីថ្ងៃចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ។

## ប្រការ ១៨._ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិជាម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម ម្ចាស់ម៉ាកត្រូវភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃបទបញ្ជារួមស្តីពីការគ្រប់គ្រងនៃការប្រើប្រាស់ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម ដោយមានការបញ្ជាក់ពីភាពត្រឹមត្រូវ។ ការខកខានមិនបានដាក់ជូនបទបញ្ជារួមស្តីពី ការគ្រប់គ្រងនៃការប្រើប្រាស់ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម នឹងត្រូវបានបដិសេធកិច្ចការពារម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្មនោះ ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ប្រការ ១៩._ ការធ្វើមោឃភាព

នៅពេលការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានធ្វើមោឃភាពក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមោឃភាពនោះលែងជាកម្មវត្ថុចំពោះបណ្តឹងតវ៉ា នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ស្របតាមបទប្បញ្ញត្តិនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

**ប្រការ ២០._ ការកត់ត្រាក្នុងបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ**

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ការកត់ត្រាណាមួយដែលបានធ្វើឡើងក្នុងបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវមានអានុភាពដូចការកត់ត្រានៅក្នុងបញ្ជីម៉ាកដែលបានធ្វើឡើងនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មផងដែរ។

**ប្រការ២១._ កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ**

កិច្ចសន្យាផ្តល់អាជ្ញាបណ្ណ័ទាក់ទងនឹងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលត្រូវបានកត់ត្រាដោយការិយាល័យអន្តរជាតិ មិនមានអានុភាពចំពោះព្រះរាជាណាចក្រកម្ពុជាឡើយ។

**ប្រការ២២._ លិខិតបញ្ជាក់ការប្រើប្រាស់ ឬមិនបានប្រើប្រាស់**

(១) ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាកអន្តរជាតិរួចហើយ ត្រូវដាក់លិខិតបញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មក្នុងអំឡុងពេល ១(មួយ)ឆ្នាំ បន្ទាប់ពីខួបលើកទី ៥ នៃកាលបរិច្ឆេទផ្តល់កិច្ចការពារក្នុងព្រះរាជាណាចក្រកម្ពុជា ឬកាលបរិច្ឆេទផ្តល់កិច្ចការពារសាជាថ្មី ។ ម្ចាស់ម៉ាក ត្រូវបំពេញពាក្យស្នើសុំដែលបានកំណត់ ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

(២) ក្នុងករណីដែលម្ចាស់ម៉ាកខកខានមិនបានដាក់លិខិតបញ្ជាក់ការប្រើប្រាស់ ឬមិនបានប្រើប្រាស់ក្នុងអំឡុងពេលដែលបានកំណត់ដោយច្បាប់ និងអនុក្រឹត្យស្តីពីម៉ាក ម៉ាកដែលបានចុះបញ្ជីនោះនឹងលែងទទួលបានកិច្ចការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីបញ្ហានេះ ។

**ប្រការ២៣._ ការជំនួសការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ ដោយការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ**

ម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ អាចស្នើសុំនាយកដ្ឋានកម្មសិទ្ធិបញ្ញាឲ្យជំនួសការកត់ត្រាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ ទៅជាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

**ប្រការ២៤._ ការសុំប្តូរពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទៅជាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ**

ម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ អាចស្នើនាយកដ្ឋានកម្មសិទ្ធិបញ្ញាសុំប្តូរពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទៅជាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ២៥._ បដិវាទកម្ម**

ក្នុងករណីមានទំនាស់រវាងប្រការទាំងឡាយនៃប្រកាសនេះ និងបទប្បញ្ញត្តិអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ត្រូវអនុវត្តតាមមាត្រា ៦០ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៦._ ប្រសិទ្ធភាពអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

<u>ចម្លងជូន៖</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ ។